ភ្នំពេញ,ថ្ងៃទី  ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥

# សេចក្តីប្រកាសព័ត៌មានរួមរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង  អង្គការសុខភាពពិភពលោក

## គ្មានភ័ស្តុតាងបញ្ជាក់ថាមានការប្រែប្រួលរូបរាងរបស់មេរោគផ្តាសាយបក្សីនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ

ថ្មីៗនេះមានសារព័ត៌មានមួយចំនួនបានផ្សាយថា  មានការផ្លាស់ប្តូររូបរាងមេរោគផ្តាសាយបក្សី  ដែលគេបានវត្ថុវិភាគពីអ្នកជំងឺនៅក្នុងព្រះរាជាណាចក្រកម្ពុជា  ។  ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា  និង អង្គការសុខភាពពិភពលោកសូមបញ្ជាក់ថា  គ្មានភ័ស្តុតាងបញ្ជាក់ថាមានការប្រែប្រួលរូបរាងនៃមេរោគផ្តាសាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ។

ប្រទេសកម្ពុជាបានរាយការណ៍  ៤ករណីជំងឺផ្តាសាយបក្សីនៅក្នុងឆ្នាំ  ២០០៥  នេះ,  បន្ទាប់ពីនេះពុំមានករណីផ្សេងទៀតបានរកឃើញចាប់តាំងពីខែមេសា ឆ្នាំ ២០០៥ មក ។ វត្ថុវិភាគទាំងបួននៃអ្នកជំងឺទាំងនេះ បានផ្ញើទៅមន្ទីរពិសោធន៍សហប្រតិបត្តិការរបស់អង្គការសុខភាពពិភពលោក  ដែលរកឃើញថា  វត្ថុវិភាគពីប្រទេសកម្ពុជា មានរូបរាងដូចទៅនឹងមេរោគ ដែលបានរកឃើញពីប្រទេសដទៃនៅក្នុងតំបន់ ។

មេរោគ  ឬ  វីរុស  អាំងហ្វ្លុយអង់សា  ជាទូទៅគឺមិនទៀងទាត់និងតែងតែផ្លាស់ប្តូរបន្តិចបន្តួចនូវរូបរាងរបស់វា  ។ ប៉ុន្តែការផ្លាស់ផ្តូរបន្តិចបន្តួចនេះ  មិនផ្លាស់ប្តូរនូវលក្ខណៈទូទៅរបស់វាទេ  ។  វីរុសពីប្រទេសកម្ពុជាបានបង្ហាញថាមានការផ្លាស់ប្តូររូបរាងបន្តិចបន្តួច  ដែលជាការប្រែប្រួលជាធម្មតារបស់វីរុសនេះ   ទោះបីយ៉ាងណាក៏ដោយក៏គ្មានភ័ស្តុតាងនៅឡើយ  ដែលមានការផ្លាស់ប្តូរខ្លាំងដែលបណ្តាលឱ្យវាអាចងាយស្រួលក្នុងការឆ្លងពីសត្វបក្សីទៅមនុស្សដែរ ។

ក្នុងពេលដែលមានការរាយការណ៍ថាមានជំងឺនេះនៅក្នុងប្រទេសកម្ពុជា   ក្រុមអង្កេតស្រាវជ្រាវបានធ្វើការរុករកដើម្បីរកភ័ស្តុតាងឱ្យឃើញថា វីរុសនេះខានផ្លាស់ប្តូរ និងប្រែប្រួលលទ្ធភាពក៏រិតឆ្លងរបស់វា ។ ប៉ុន្តែគ្មានបានរកឃើញថា  វាមានការប្រែប្រួល  និង  មានលទ្ធភាពឆ្លងពីសត្វបក្សីទៅមនុស្សខ្លាំង  និង  ពីមនុស្សទៅមនុស្ស

នៅឡើយផងដែរ ។ ការសិក្សាមន្ទីរពិសោធន៍ទៅលើវីរុសផ្ដាស់សាយបក្សីពីប្រទេសនានានៅតែបន្ត ដើម្បីយល់កាន់តែច្រើនអំពីសណ្ឋានវីរុស និង សមត្ថភាពឆ្លងរបស់វា ។
ក្រសួងសុខាភិបាល ក្រោមការជួយឧបត្ថម្ភពីអង្គការសុខភាពពិភពលោក, វិទ្យាស្ថានប៉ាស្ទ័រនៅកម្ពុជា និង ដៃគូរដ៏ទៃទៀត នៅតែបន្តជួយពង្រឹងប្រព័ន្ធតាមដាន និង ឆ្លើយតបទៅនឹងជំងឺឆ្លងទៅលើជំងឺផ្ដាសាយបក្សី ។ ការពង្រឹងប្រព័ន្ធតាមដានជំងឺឆ្លង ក្នុងគោលដៅដើម្បីរកឃើញឱ្យទាន់ពេលវេលានូវករណីដំបូង, ពង្រឹងសមត្ថភាពអង្កេតស្រាវជ្រាវ និង ផ្ដល់គាំទ្រការធ្វើរោគវិនិច្ឆ័យដោយមន្ទីរពិសោធន៍ពីវិទ្យាស្ថានប៉ាស្ទ័រនៅក្នុងប្រទេសកម្ពុជា ក្នុងកំឡុ ២៤ម៉ោង ក្រោយពីទទួលបានវត្ថុវិភាគ ។

-----------------------------

ពត៌មានបន្ថែមសូមទាក់ទងទូរស័ព្ទ :

ក្រសួងសុខាភិបាល :

វេជ្ជ. សុខ ទូច : ០១២ ៨៥៦ ៨៤៨,          វេជ្ជ. លី សូវ៉ាន់ : ០១២ ៨២៥ ៤២៤

អង្គការសុខភាពពិភពលោក :

វេជ្ជ. ផូល វីលឡិន : ០១២ ៩០៥ ៥០១,     បណ្ឌិត មែក មីលឡឺ : ០១២ ៤៤៣ ៨៧៧